# សេចក្ដីព្រាងច្បាប់
# ស្ដីពី
# សិទ្ធិជនពិការ

✱✱✱✱

## ជំពូកទី ១: បទបញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងពង្រឹងការការពារសិទ្ធិ និងអត្ថប្រយោជន៍នៃជនពិការ និងប្រឆាំងការរើសអើងនានា សំដៅធានាការចូលរួមដ៏ពេញលេញ និងស្មើភាពនៃជនពិការទៅក្នុងសកម្មភាពនានា នៃសង្គមដូចពលរដ្ឋធម្មតា ។

**មាត្រា ២.-**

ជនពិការគឺពលរដ្ឋទាំងឡាយណាដែលខ្វះខាត បាត់បង់ ខូចខាតសរីរាង្គណាមួយ ឬ អន់ខ្សោយសតិបញ្ញា ដែលបណ្ដាលឱ្យមានការរំខានដល់ជីវភាពរស់នៅ ឬ សកម្មភាពនានាប្រចាំថ្ងៃ ដូចជាជនពិការរាងកាយ ពិការភ្នែក ពិការក្នុងការស្ដាប់ ពិការសតិបញ្ញា ។ល។ ដែលនាំឱ្យមានលក្ខណៈខុសសភាពធម្មតានៃមនុស្ស និងមានលិខិតបញ្ជាក់ដែលចេញ ដោយក្រសួងសុខាភិបាល ។

លក្ខណៈវិនិច្ឆ័យប្រភេទ និងកំរិតនៃពិការភាពត្រូវកំណត់ដោយអនុក្រិត្យ ។

បែបបទនៃការចេញលិខិតបញ្ជាក់ខាងលើត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសុខាភិបាល ។

**មាត្រា ៣.-**

ជនពិការមានសិទ្ធិក្នុងការអនុវត្តន៍ពេញលេញនូវសិទ្ធិជាពលរដ្ឋ ដែលធានាដោយរដ្ឋធម្មនុញ្ញ និងបណ្ដាច្បាប់អន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជា ឱ្យសច្ចាប័នមានជាអាទិ៍ សិទ្ធិរស់រានមានជីវិត សិទ្ធិទទួលសេវាផ្នែកសុខភាព សិទ្ធិចល័តនិងផ្លាស់ប្ដូរទីកន្លែង សិទ្ធិសិក្សាអប់រំ សិទ្ធិប្រកបការងារ សិទ្ធិនយោបាយ សិទ្ធិក្នុងការប្រើប្រាស់សេវាឯកជន និង សេវាសាធារណៈដទៃទៀត ។

**មាត្រា ៤.-**

ជនពិការព្រមទាំងគ្រួសារត្រូវតែបានអញ្ជើញឱ្យចូលរួមក្នុងការរៀបចំគំរោងផែនការ និងការអនុវត្តន៍កម្មវិធីដែលទាក់ទងដល់ផលប្រយោជន៍របស់ខ្លួន ។ រាល់សេចក្ដីត្រូវការរបស់ជនពិការ ត្រូវដាក់បញ្ចូលទៅក្នុងកម្មវិធីអនុវត្តនានា ឱ្យបានជាអតិបរិមា ។

**មាត្រា ៥.-**

រាជរដ្ឋាភិបាលត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវការយល់ដឹងជាសាធារណៈអំពីពិការភាព ដើម្បីពង្រឹងសាមគ្គីភាព ការយោគយល់ និងការគោរពសិទ្ធិជនពិការ ។

**មាត្រា ៦.-**

ទិវាជនពិការកម្ពុជា ត្រូវរៀបចំឡើងក្នុងគោលបំណងបំផុសការយល់ដឹងជាសាធារណៈ អំពីសុខុមាលភាព នៃជនពិការ និងលើកទឹកចិត្តជនពិការ ដើម្បីចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងសកម្មភាពផ្សេងៗទៀត ។

ទិវាជនពិការកម្ពុជាត្រូវប្រព្រឹត្តទៅរួមគ្នាជាមួយទិវាជនពិការអន្តរជាតិនាថ្ងៃទី៣ធ្នូ ជារៀងរាល់ឆ្នាំ ។

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា មានភារកិច្ចរៀបចំទិវានេះ ។

**មាត្រា ៧.-**

គណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកកម្ពុជាត្រូវរៀបចំទិវាកីឡាជនពិការមួយដងក្នុងមួយឆ្នាំ ។

## ជំពូកទី ២: ជីវភាពរស់នៅ

**មាត្រា ៨.-**

រាជរដ្ឋាភិបាលត្រូវយកចិត្តទុកដាក់ ជួយលើកដំកើងជីវភាពរស់នៅរបស់ជនពិការ ឱ្យបានសមរម្យ រួមមានចំណីអាហារ សំលៀកបំពាក់ ទីកន្លែងស្នាក់នៅ និងបង្កលក្ខណៈដល់ការរស់នៅក្នុងបរិយាកាសល្អប្រសើរ ។

**មាត្រា ៩.-**

រាជរដ្ឋាភិបាលត្រូវមានវិធានការចាំបាច់នានា ដើម្បីបំផុសលើកទឹកចិត្តពលរដ្ឋ សប្បុរសជន អង្គការសង្គម នានា ឱ្យចូលរួមក្នុងការជួយឧបត្ថម្ភ ជាពិសេសដល់ជនពិការដែលមានពិការធ្ងន់ធ្ងរ ក្រីក្របំផុត និងគ្មានទីពឹងនៅក្នុងសង្គមជាតិ ។

**មាត្រា ១០.-**

រាជរដ្ឋាភិបាលត្រូវមានថវិកាប្រចាំឆ្នាំ ដើម្បីជួយឧបត្ថម្ភដល់ជនពិការដែល :

- មានពិការធ្ងន់ធ្ងរ ក្រីក្របំផុត និងគ្មានទីពឹង
- ចាស់ជរា ក្រីក្របំផុត និងគ្មានទីពឹង
- មានគ្រោះថ្នាក់ធ្ងន់ធ្ងរ ។

រាជរដ្ឋាភិបាល ត្រូវលើកទឹកចិត្តដល់ការធ្វើសមាហរណកម្មជនពិការ ទៅក្នុងសហគមន៍ ។ កម្មវិធីនៃការធ្វើសមាហរណកម្មនេះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា និងក្រសួងពាក់ព័ន្ធ ។

**មាត្រា ១១.-**

រាជរដ្ឋាភិបាល ត្រូវរៀបចំឱ្យមានរបបសន្តិសុខសង្គម សំរាប់ជនពិការមានកំរិតធ្ងន់ធ្ងរ ក្រីក្របំផុត និងគ្មានទីពឹង ។

**មាត្រា ១២.-**

មាតាបិតា និងអាណាព្យាបាលជនពិការត្រូវ :

- ការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ជនពិការ
- យកចិត្តទុកដាក់បីបាច់ថែរក្សាជនពិការឱ្យបានល្អ
- លើកទឹកចិត្ត និងជួយជនពិការឱ្យមានក្តីសង្ឃឹមក្នុងជីវិត ។

ការមិនយកចិត្តទុកដាក់ថែទាំ ការកេងប្រវ័ញ្ច និងការបោះបង់ជនពិការត្រូវហាមឃាត់ ។

## ជំពូកទី ៣: ការស្តារកាយសម្បទា និងសតិបញ្ញា សុខភាព និងបង្ការ

**មាត្រា ១៣.-**

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ត្រូវរៀបចំកម្មវិធីស្តារកាយសម្បទា និងសតិបញ្ញា សំដៅជួយដល់ជនពិការឱ្យទទួលបានមុខងារ និងសកម្មភាពដូច ឬ ប្រហាក់ប្រហែលនឹងមនុស្សធម្មតា ដើម្បីឱ្យជនពិការ មានលទ្ធភាពប្រើប្រាស់សមត្ថភាព និងទេពកោសល្យទៅក្នុងជីវភាពសង្គម ។

**មាត្រា ១៤.-**

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ត្រូវបង្កើត និងលើកទឹកចិត្តឱ្យមានការបង្កើតជាឯកជន នូវរោងជាង ឬមជ្ឈមណ្ឌលស្តារកាយសម្បទា និងសតិបញ្ញា ដើម្បីធានាការផ្តល់សេវាដល់ជនពិការ ។

**មាត្រា ១៥.-**

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាត្រូវបង្កើត :

- សាលាសំរាប់បណ្តុះបណ្តាលអ្នកបច្ចេកទេសផលិតឧបករណ៍ទ្រទ្រង់រាងកាយ
- រោងចក្រផលិតគ្រឿងផ្សំឧបករណ៍ទ្រទ្រង់រាងកាយ

ដើម្បីធានាសេចក្ដីត្រូវការ នៃមជ្ឈមណ្ឌលស្ដារកាយសម្បទានានា ក្នុងការផ្ដល់ឧបករណ៍ទ្រទ្រង់រាងកាយ ដល់ជនពិការ ។

**មាត្រា ១៦.-**

ក្រសួងសុខាភិបាលត្រូវសហការជាមួយក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ពង្រីកកម្មវិធីបណ្ដុះបណ្ដាលបច្ចេកទេសព្យាបាលដោយចលនា និងព្យាបាលសតិបញ្ញា នៅតាមសាលាបច្ចេកទេសថែទាំវេជ្ជសាស្ត្រនានា ហើយបញ្ចូលផ្នែកនេះ ឱ្យមានគ្រប់មន្ទីរពេទ្យ ដើម្បីព្យាបាលអ្នកជំងឺកុំឱ្យធ្លាក់ខ្លួនពិការ ។

**មាត្រា ១៧.-**

ក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទាត្រូវសហការជាមួយក្រសួងសុខាភិបាល ជួយបណ្ដុះបណ្ដាលគ្រួសារដែលមានសមាជិកពិការ និងអ្នកស្ម័គ្រចិត្ត អំពីវិធីថែទាំ និងបច្ចេកទេសស្ដារតាមប្រភេទពិការនីមួយៗ ដើម្បីឱ្យគ្រួសារដែលមានសមាជិកពិការមានលទ្ធភាពស្ដារកាយសម្បទា និងសតិបញ្ញាជនពិការ ។

**មាត្រា ១៨.-**

ក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា និងក្រសួងសុខាភិបាលត្រូវពង្រីកសេវាស្ដារលទ្ធភាពពលកម្មតាមសហគមន៍ សេវាពិគ្រោះយោបល់ ព្យាបាលជម្ងឺផ្លូវចិត្ត និងសតិបញ្ញាយឺតយ៉ាវ ។

**មាត្រា ១៩.-**

រាជរដ្ឋាភិបាល ត្រូវបង្កើតកម្មវិធីបង្ការពិការភាពដល់ពលរដ្ឋគ្រប់រូបតាមរយៈ :

- ការថែទាំសុខភាពក្នុងពេលមានគភ៌ និងក្រោយពេលមានគភ៌
- ការតាមដាន និងការវិនិច្ឆ័យរោគដែលនាំឱ្យមានពិការភាពទាន់ពេលវេលា
- ការចាក់ថ្នាំបង្ការជំងឺដែលនាំឱ្យពិការ
- ការផ្ដល់អាហារទ្រទ្រង់រាងកាយ
- ការអប់រំអំពីមូលហេតុដែលនាំឱ្យមានពិការភាព
- ការព្យាបាលតាមវិធីវេជ្ជសាស្ត្រ និងការអប់រំកាយសម្បទាឡើងវិញឱ្យទាន់ពេលវេលា ។ល។

**មាត្រា ២០.-**

រាជរដ្ឋាភិបាលត្រូវជួយឧបត្ថម្ភសេវាពិនិត្យថែទាំសុខភាព និងព្យាបាលដល់ជនពិការ ដែលមានពិការភាពធ្ងន់ធ្ងរ ឬ ក្រីក្រគ្មានទីពឹង ។

# ជំពូកទី ៤: ការចេញចូលជាសាធារណៈ

**មាត្រា ២១.-**

ពាក្យ "ទីកន្លែងសាធារណៈ" ក្នុងច្បាប់នេះមានន័យថា បរិវេណ អគារ ទីតាំង និងមធ្យោបាយដឹកជញ្ជូននានា ដែលជាកម្មសិទ្ធិរដ្ឋ សាធារណៈ ឬ ឯកជនដែលបើកទូលាយ និងផ្តល់សេវាដល់សាធារណជនទូទៅដូចជា ក្រសួង មន្ទីរ ស្ថាប័ន ផ្លូវថ្នល់ កន្លែងលំហែកាយ មជ្ឈមណ្ឌលវប្បធម៌ កន្លែងលេងកីឡា កន្លែងកំសាន្ត គ្រឹះស្ថានអប់រំ សណ្ឋាគារ មន្ទីរពេទ្យ មជ្ឈមណ្ឌលសុខភាព អាហារដ្ឋាន ប្រព័ន្ធដឹកជញ្ជូន ។ល។

**មាត្រា ២២.-**

រាល់ទីកន្លែងសាធារណៈទាំងឡាយដែលកំពុងសាងសង់ ឬ មានគំរោងនឹងសាងសង់នៅថ្ងៃអនាគតត្រូវរៀបចំ សំរួលដល់លទ្ធភាពចេញចូល របស់ជនពិការគ្រប់ប្រភេទដូចជា ការធ្វើជំរាល ការបំពាក់ឧបករណ៍ផ្ទាក់ដៃនៅតាម បន្ទប់ទឹក ការដាក់ផ្លាកសញ្ញានានា ។ល ។

**មាត្រា ២៣.-**

ទីកន្លែងសាធារណៈទាំងឡាយណាដែលបានសាងសង់រួចមុនច្បាប់នេះចូលជាធរមាន ហើយមិនទាន់បានរៀបចំ សំរួលដូចមានចែងក្នុងមាត្រា ២២ ខាងលើ ត្រូវរៀបចំលើកគំរោង និងកែសំរួលទីកន្លែងសាធារណៈនោះ ដើម្បីឱ្យ ជនពិការមានលទ្ធភាពចេញចូលបាន ។ ការលើកគំរោងរៀបចំ ដើម្បីកែសំរួលទីកន្លែងនេះ អាចលើកលែងទៅបាន តែក្នុងករណីដែលនិយោជក ឬ ម្ចាស់ទីកន្លែងសាធារណៈ បង្ហាញច្បាស់ថាមានអប្រតិបត្តិភាពលើរចនាសម្ព័ន្ធ ឬ ត្រូវការចំណាយ ច្រើនហួសហេតុ ។

**មាត្រា ២៤.-**

ក្រសួងមានសមត្ថកិច្ចដែលពាក់ព័ន្ធត្រូវសហការក្នុងការផ្តល់ការអនុញ្ញាតលើគំរោងសាងសង់ ការសាងសង់ និង ត្រួតពិនិត្យសំណង់ទីកន្លែងសាធារណៈ ដើម្បីធានានូវលទ្ធភាពចេញចូលរបស់ជនពិការ ដូចមានចែងក្នុងមាត្រា ២២ ។

**មាត្រា ២៥.-**

ការណែនាំស្តីពីការរៀបចំលទ្ធភាពចេញចូលរបស់ជនពិការដូចមានចែងក្នុងមាត្រា ២២, ២៣ និង ២៤ ត្រូវ កំណត់ដោយប្រកាសរបស់ក្រសួងមានសមត្ថកិច្ច ។

**មាត្រា ២៦.-**

ជនពិការមានសិទ្ធិទទួលប័ណ្ណបើកបរយានយន្ត ។ សមត្ថភាពបើកបរយានយន្តនៃជនពិការ ព្រមទាំងប្រភេទ យានយន្តសំរាប់ជនពិការត្រូវកំណត់ដោយប្រកាសរួមនៃក្រសួងសុខាភិបាល និងក្រសួងសាធារណៈការ និងដឹកជញ្ជូន ។

**មាត្រា ២៧.-**

ក្រសួងសាធារណៈការ និងដឹកជញ្ជូន ត្រូវចេញប័ណ្ណសំគាល់យានយន្តដែលជនពិការបើកបរ ។ ជនពិការដែលបើកបរយានយន្ត អាចដាក់បង្ហាញប័ណ្ណនេះនៅជាប់នឹងយានយន្តរបស់ខ្លួន ដើម្បីឱ្យអ្នកដទៃមើលឃើញ ។ ជនពិការ ត្រូវដាក់បង្ហាញប័ណ្ណនេះនៅជាប់នឹងយានយន្តរបស់ខ្លួននៅពេលចតលើចំណតសំរាប់ជនពិការ ។

**មាត្រា ២៨.-**

ក្រសួងសាធារណៈការ និងដឹកជញ្ជូន ត្រូវចេញប្រកាសឱ្យមានការបំរុងកន្លែងចតយានយន្ត សំរាប់ជនពិការក្នុងចំណតសាធារណៈ និងឯកជន ។

## ជំពូកទី ៥: ការអប់រំ

**មាត្រា ២៩.-**

ពាក្យ "គ្រឹះស្ថានអប់រំ" នៅក្នុងច្បាប់នេះ គឺសំដៅដល់សាលារដ្ឋ និងសាធារណៈ ឬ ឯកជនទាំងឡាយណា ដែលរាជរដ្ឋាភិបាលអនុញ្ញាតឱ្យបង្កើតសំរាប់អប់រំបណ្តុះបណ្តាលសិស្សគ្រប់វ័យ ។ ពាក្យនេះរាប់បញ្ចូលចាប់ពីកំរិតមត្តេយ្យសិក្សាឡើងទៅ ។

**មាត្រា ៣០.-**

"សិស្សពិការមានគុណសម្បត្តិ" នៅក្នុងច្បាប់នេះគឺសំដៅដល់ជនពិការគ្រប់វ័យ ដែលមានបំណងចូល សិក្សា កំពុងសិក្សា និងបន្តការសិក្សា ហើយអាចបំពេញនូវកម្មវិធីរបស់គ្រឹះស្ថានអប់រំនោះបាន ដោយមានការសំរបសំរួលផ្នែកខ្លះៗដូចជា :

- បន្ទប់ និងកន្លែងសិក្សា
- បច្ចេកទេសអប់រំ និងគរុកោសល្យស្របទៅតាមពិការភាព
- សំភារៈសិក្សា ឬ ឧបករណ៍ផ្សេងៗសំរាប់ជំនួយដល់សិស្សពិការ
- សំភារៈឧបទេសសំរាប់គ្រូបង្រៀន ឬ សាស្ត្រាចារ្យ

លើសពីនេះជួយសំរួលដល់ផ្នែកផ្សេងៗទៀតតាមការជាក់ស្តែងរបស់សិស្សពិការម្នាក់ៗ ។

**មាត្រា ៣១.-**

សិស្សពិការមានគុណសម្បត្តិគ្រប់រូបមានសិទ្ធិចូលសិក្សាក្នុងគ្រឹះស្ថានអប់រំ និងទទួលអាហារូបករណ៍ដូចសិស្សដទៃទៀតដែរ លើកលែងតែមានបញ្ញត្តិដែលសមស្របចែងផ្ទុយពីនេះ ។

**មាត្រា ៣២.-**

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវយកចិត្តទុកដាក់ជាពិសេសដល់សេចក្តីត្រូវការផ្នែកអប់រំរបស់សិស្សពិការ ។

សិស្សពិការមានគុណសម្បត្តិក្នុងគ្រួសារក្រីក្រ ត្រូវបានចូលសិក្សានៅតាមគ្រឹះស្ថានអប់រំរដ្ឋ និងសាធារណៈ ដោយឥតបង់ថ្លៃ ។

សាលាឯកជនត្រូវចុះថ្លៃការសិក្សាសំរាប់សិស្សពិការ ។

រាល់សៀវភៅសិក្សា និងសំភារៈសិក្សារបស់គ្រឹះស្ថានអប់រំរដ្ឋ និងសាធារណៈត្រូវចុះថ្លៃសំរាប់សិស្សពិការ ។

**មាត្រា ៣៣.-**

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវដាក់បញ្ចូលក្នុងកម្មវិធីចំណេះដឹងទូទៅ សំរាប់សិស្សគ្រប់រូបឱ្យយល់ដឹងពីមូលហេតុនៃពិការភាព វិធីការពារពិការភាព និងតំលៃរបស់ជនពិការ ។ល។

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវមានកម្មវិធីគរុកោសល្យសំរាប់សិស្សពិការ ដើម្បីបំពាក់បំប៉នគ្រូ និងសាស្រ្តាចារ្យគ្រប់រូបឱ្យយល់ដឹងពីពិការភាព និងវិធីសាស្រ្តបង្រៀនសិស្សពិការ ។

**មាត្រា ៣៤.-**

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបង្កើតគោលនយោបាយ និងយុទ្ធសាស្រ្តជាតិ សំរាប់អប់រំសិស្សពិការដូចជា:

- ការជំរុញធ្វើសមាហរណកម្មសិស្សពិការ ទៅក្នុងថ្នាក់រៀនចំរុះ តាមដែលអាចធ្វើទៅបាន ។
- ការបង្កើតថ្នាក់រៀនពិសេស សំរាប់ឆ្លើយតបនឹងសេចក្តីត្រូវការនៃសិស្សពិការ ។

## ជំពូកទី ៦: ការងារ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ

**មាត្រា ៣៥.-**

"ជនពិការមានគុណសម្បត្តិ" នៅក្នុងច្បាប់នេះ គឺជនពិការទាំងឡាយណា ដែលមានសមត្ថភាពបំពេញនូវមុខងារ តួនាទី និងការទទួលខុសត្រូវនៅក្នុងមុខតំណែង ដែលជននោះកាន់កាប់ ឬ ប្រាថ្នាចង់កាន់កាប់ ។

**មាត្រា ៣៦.-**

"និយោជិត" នៅក្នុងច្បាប់នេះ គឺជាជនពិការ ដែលបានចុះកិច្ចសន្យាការងារធ្វើការឱ្យនិយោជកដោយយកកំរៃក្រោមការគ្រប់គ្រងរបស់និយោជក ឬ តំណាងនៃនិយោជកដូចមានកំណត់នៅក្នុងច្បាប់ស្តីពីការងារ និងច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល ។

"និយោជក" នៅក្នុងច្បាប់នេះ គឺរូបវន្តបុគ្គល ឬ នីតិបុគ្គលជារដ្ឋ ឬ សាធារណៈ ឬ ឯកជនទាំងអស់ ដែលជាអ្នកជួលនិយោជិតឱ្យបំរើការងារដូចមានកំណត់នៅក្នុងច្បាប់ស្តីពីការងារ និងច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ។

**មាត្រា ៣៧.-**

ជនពិការមានគុណសម្បត្តិ មានសិទ្ធិចូលបំរើការងារដោយគ្មានការរើសអើង រាប់ទាំងការបំរើការងារក្នុងឋានៈជាកូនជាង ឬ កម្មសិក្សាការីផងដែរ ។ ការរើសអើងនេះសំដៅគ្រប់កាលៈទេសៈទាំងអស់ដូចជា ការសុំចូលបំរើការងារ ការទទួលបៀវត្ស ការតម្លើងឋានៈ ការបញ្ឈប់ពីការងារ សំណង ការបណ្តុះបណ្តាល និងល័ក្ខខ័ណ្ឌផ្សេងៗទៀត ។

**មាត្រា ៣៨.-**

និយោជកដែលជ្រើសរើសកម្មករ និយោជិតធ្វើការពេញម៉ោងក្នុងចំនួនកំណត់ ត្រូវទទួលយកជនពិការឱ្យចូលធ្វើការពេញម៉ោងតាមអត្រាកំណត់សមស្រប ។

**មាត្រា ៣៩.-**

និយោជក ដែលត្រូវទទួលជនពិការឱ្យចូលធ្វើការពេញម៉ោងតាមអត្រាកំណត់សមស្រប ត្រូវធ្វើសេចក្តីប្រកាសជាកាលិកអំពីចំនួនកម្មករ និយោជិតធ្វើការពេញម៉ោង និងកម្មករ និយោជិតជាជនពិការធ្វើការពេញម៉ោង ទៅក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

**មាត្រា ៤០.-**

និយោជក ដែលមិនបានបំពេញតាមលក្ខខណ្ឌ ដូចមានចែងក្នុងមាត្រាទី ៣៨ ត្រូវបង់វិភាគទានចូលហិបមូលនិធិនៃជនពិការ ។

**មាត្រា ៤១.-**

និយោជក ត្រូវរៀបចំឱ្យមានការសំរបសំរួលសមស្រប សំរាប់ជនពិការមានគុណសម្បត្តិ ដែលជាបេក្ខជនដាក់ពាក្យសុំបំរើការងារ ឬ និយោជិត ឬ កូនជាង ឬ កម្មសិក្សាការី លើកលែងតែក្នុងករណីការសំរបសំរួលនោះមានបន្ទុកធ្ងន់ធ្ងរហួសហេតុ ។

**មាត្រា ៤២.-**

- "ការសម្របសម្រួលសមស្រប" នៅក្នុងច្បាប់នេះ សំដៅលើៈ
  - ក/ ការរៀបចំនូវគ្រឿងសំភារៈប្រើប្រាស់ ដែលមានស្រាប់នៅនឹងកន្លែងធ្វើការ ឬ កែតំរូវផ្លាស់ប្តូរនូវគ្រឿងឧបករណ៍ និងសំភារៈផ្សេងៗ ដើម្បីឱ្យជនពិការអាចប្រើប្រាស់បាន ។
  - ខ/ ការរៀបចំរចនាសម្ព័ន្ធការងារ កាលវិភាគការងារ ឬ ផ្លាស់ប្តូរវិញ្ញាសារប្រឡង ឬ បង្កលក្ខណៈងាយស្រួល តាមរយៈការរៀបចំគោលនយោបាយឡើងវិញ ដើម្បីផ្តល់នូវសេវា និងការសម្របសម្រួលស្រដៀងគ្នាដទៃទៀតដល់ជនពិការ ។

▪ "បន្ទុកធ្ងន់ធ្ងរហួសហេតុ" នៅក្នុងច្បាប់នេះ សំដៅលើវិធានការនៃការសំរបសំរួលសមស្របទាំងឡាយណាដែលធ្វើទៅមានការលំបាកខ្លាំង ឬ ត្រូវចំណាយថវិកាច្រើន ។ ដើម្បីកំណត់ថាតើវិធានការណាមួយ បណ្តាលឱ្យមានបន្ទុកធ្ងន់ធ្ងរហួសហេតុ ត្រូវពិនិត្យមើលកត្តាទាំងឡាយដូចខាងក្រោមនេះ :

ក/ ថ្លៃចំណាយសម្រាប់វិធានការសំរបសំរួលនោះ

ខ/ ប្រភពធនធានហិរញ្ញវត្ថុ និងតំលៃសរុបនៃគ្រឿងសំភារៈបរិក្ខា

គ/ សភាពលក្ខណៈនៃចំនួននិយោជិត ឬ កូនជាង ឬ កម្មសិក្សាការី លក្ខណៈទីតាំង ឥទ្ធិពល ឬ ផលដែលអាចប៉ះពាល់ បណ្តាលមកពីការសម្របសម្រួលនោះ ។

**មាត្រា ៤៣.-**

ស្ថាប័នបណ្តុះបណ្តាលវិជ្ជាជីវៈរបស់រដ្ឋ ឬ សាធារណៈ ឬ ឯកជន ត្រូវទទួលបណ្តុះបណ្តាលជនពិការមានគុណសម្បត្តិ ។

**មាត្រា ៤៤.-**

ស្ថាប័នបណ្តុះបណ្តាលវិជ្ជាជីវៈរបស់រដ្ឋ ឬ សាធារណៈ ឬ ឯកជន ត្រូវរៀបចំការសម្របសម្រួលសមស្របដល់ជនពិការមានគុណសម្បត្តិ ដែលជាបេក្ខជនដាក់ពាក្យសុំចូលសិក្សា ឬ ជាសិក្ខាកាម ឬ ជាកម្មសិក្សាការី លើកលែងតែក្នុងករណីការសម្របសម្រួលនោះមានបន្ទុកធ្ងន់ធ្ងរហួសហេតុ ។

**មាត្រា ៤៥.-**

ស្ថាប័នបណ្តុះបណ្តាលវិជ្ជាជីវៈរបស់រដ្ឋ ឬ សាធារណៈ ឬ ឯកជន ត្រូវរៀបចំកម្មវិធីបណ្តុះបណ្តាលលំអិតជាលាយលក្ខណ៍អក្សរ រួចប្រកាសផ្សាយឱ្យជនពិការបានដឹងជាមុន ។ កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈនេះ ត្រូវចាត់ទុកជាភស្តុតាងនៃការទទួលខុសត្រូវ និងភារកិច្ចក្នុងការបំពេញមុខងារសំខាន់ៗរបស់កម្មវិធី ។

## ជំពូកទី ៧: កម្មវិធីលើកទឹកចិត្ត

**មាត្រា ៤៦.-**

រាជរដ្ឋាភិបាលត្រូវបង្កើតកម្មវិធីលើកទឹកចិត្តដល់មុខរបរ អាជីវកម្ម សិប្បកម្មជាលក្ខណៈផ្ទាល់ខ្លួន ឬ គ្រួសារ ឬ សមូហភាពរបស់ជនពិការ តាមរយៈការកាត់បន្ថយពន្ធដារ និងការផ្តល់អាទិភាពផ្សេងៗទៀត ។

ការលើកទឹកចិត្តខាងលើត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៤៧.-**

រាជរដ្ឋាភិបាលត្រូវបង្កើតកម្មវិធីលើកទឹកចិត្តផ្នែកពន្ធដារ និងការលើកទឹកចិត្តផ្សេងៗទៀតដល់និយោជក ដែលបានទទួលជនពិការឱ្យចូលធ្វើការទៅតាមអត្រាកំណត់សមស្រប ឬ លើសអត្រាកំណត់សមស្រប ដែលមានចែងក្នុងជំពូកទី ៦ នៃច្បាប់នេះ ។

គំរិតនៃការលើកទឹកចិត្តផ្នែកពន្ធដារ និងការលើកទឹកចិត្តផ្សេងៗទៀតដូចមានចែងខាងលើនេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៤៨.-**

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងស្ថាប័នពាក់ពន្ធ័ ត្រូវផ្សព្វផ្សាយនូវកម្មវិធីលើកទឹកចិត្តដល់វិនិយោគិន និងនិយោជកឱ្យបានទូលំទូលាយ ។

**មាត្រា ៤៩.-**

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងស្ថាប័នពាក់ពន្ធ័ ត្រូវសហការក្នុងការតាមដានត្រួតពិនិត្យរាល់ការអនុវត្តន៍កម្មវិធីលើកទឹកចិត្តនេះ ។

## ជំពូកទី ៨: ការបោះឆ្នោត

**មាត្រា ៥០.-**

គ្មានជនពិការណាម្នាក់ ត្រូវបានរារាំងនូវសិទ្ធិក្នុងការចូលរួមការបោះឆ្នោត ឬ ឈរឈ្មោះជាបេក្ខជនឱ្យគេបោះឆ្នោតដោយសារពិការភាពរបស់ខ្លួននោះឡើយ ។

**មាត្រា ៥១.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវចាត់វិធានការសមស្រប ដើម្បីបង្កលក្ខណៈងាយស្រួលឱ្យជនពិការ អាចចូលបោះឆ្នោតបាន ។

**មាត្រា ៥២.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គការនានាត្រូវសហការរៀបចំកម្មវិធីផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវសិទ្ធិរបស់ជនពិការចូលរួមក្នុងការបោះឆ្នោត ។

គ្រប់កម្មវិធីផ្សព្វផ្សាយដែលទាក់ទងនឹងការបោះឆ្នោតត្រូវបញ្ចូលកម្មវិធីយល់ដឹងអំពី :

- សិទ្ធិរបស់ជនពិការក្នុងការចូលរួមការបោះឆ្នោត
- សិទ្ធិរបស់ជនពិការក្នុងការជ្រើសរើសអ្នកជំនួយ

- នីតិវិធី និងបែបបទនៃការបំពេញកិច្ចព្រមព្រៀងរវាងជនពិការ និងអ្នកជំនួយមុនពេលចូលទៅក្នុងបន្ទប់បោះឆ្នោត
- វិធានការសមស្រប និងការបង្កលក្ខណៈងាយស្រួលដល់ជនពិការក្នុងការបោះឆ្នោត ។

# ជំពូកទី ៩: ក្រុមប្រឹក្សាសកម្មភាពជនពិការ

**មាត្រា ៥៣.-**

ក្រុមប្រឹក្សាសកម្មភាពជនពិការ មានអក្សរកាត់ថា "កសព" ជាយន្តការសំរបសំរួលថ្នាក់ជាតិ និងផ្តល់យោបល់ជូនរាជរដ្ឋាភិបាលលើបញ្ហាពិការភាព ។

**មាត្រា ៥៤.-**

ក្រុមប្រឹក្សានេះ មានភារកិច្ចដូចខាងក្រោម ÷

- ផ្តល់ការពិគ្រោះយោបល់ជំនាញលើរាល់បញ្ហាពិការភាព និងស្តារលទ្ធភាពពលកម្ម
- សហការជាមួយរាជរដ្ឋាភិបាល និងអង្គការពាក់ព័ន្ធ ក្នុងការរៀបចំគោលនយោបាយ ផែនការជាតិ និងយុទ្ធសាស្ត្រ ដែលមានការពាក់ព័ន្ធទៅនឹងពិការភាព និងស្តារលទ្ធភាពពលកម្ម
- ជម្រុញការអនុវត្តន៍គោលនយោបាយ ច្បាប់ បទបញ្ញាផ្សេងៗ ដែលទាក់ទងទៅនឹងបញ្ហាពិការភាព និងស្តារលទ្ធភាពពលកម្ម
- ផ្តល់អនុសាសន៍ជូនរាជរដ្ឋាភិបាល ដើម្បីសុំកែសំរួល បំពេញបន្ថែម ឬ សុំធ្វើវិសោធនកម្មគោល នយោបាយ ច្បាប់ ឬ បទបញ្ញាផ្សេងៗ
- សហការតាមដាន វាយតម្លៃការអនុវត្តន៍គោលនយោបាយ ច្បាប់ ផែនការជាតិ និងបទបញ្ញាផ្សេងៗទៀត ។

**មាត្រា ៥៥.-**

ក្រុមប្រឹក្សាសកម្មភាពជនពិការត្រូវបានដឹកនាំដោយក្រុមប្រឹក្សាភិបាល ដែលមានមន្ត្រីជាន់ខ្ពស់ ០១រូប របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាជាប្រធាន តំណាងមកពីក្រសួងពាក់ព័ន្ធ តំណាងអង្គការជនពិការ និងតំណាងអង្គការផ្សេងៗទៀត ជាសមាជិក ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាសកម្មភាពជនពិការ ត្រូវកំណត់ដោយអនុក្រិត្យ ។

# ជំពូកទី ១០: មូលនិធិជនពិការ

**មាត្រា ៥៦.-**

មូលនិធិជនពិការ ត្រូវបានបង្កើតឡើងក្នុងគោលបំណង :

- ផ្តល់មូលនិធិសំរាប់ការអនុវត្តនីគំរោងកម្មវិធីផ្សេងៗ ដែលជួយដល់ជនពិការ និងគាំទ្រដល់ស្ថាប័ន គ្រឹះស្ថាននានា ដែលផ្តល់សេវាកម្មដល់ជនពិការ ដូចជាផ្នែកសុខាភិបាល ស្តារលទ្ធភាពពលកម្ម អប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ និងការរកការងារឱ្យធ្វើ ។
- លើកកំពស់ និងបង្កើនសុខុមាលភាពរបស់ជនពិការ ជាពិសេស :
    - ជនពិការក្រីក្រដែលមិនបានទទួលសេវាស្តារលទ្ធភាពពលកម្ម
    - គ្រួសារជនពិការក្រីក្រដែលពឹងផ្អែកលើជនពិការ ក្នុងជីវភាពរស់នៅ
    - ជនពិការក្រីក្រដែលបានទទួលសេវាស្តារលទ្ធភាពពលកម្ម ឬ ជនពិការដែលមានជំនាញ តែពុំទាន់ទទួលបានការងារធ្វើ ។
- ផ្តល់ឥណទានសំរាប់ការសំរបសំរួលសមស្រប ។

**មាត្រា ៥៧.-**

មូលនិធិជនពិការជាគ្រឹះស្ថានសាធារណៈ រដ្ឋបាលដែលត្រូវបង្កើតដោយអនុក្រិត្យ ។

**មាត្រា ៥៨.-**

ប្រភពចំណូលនៃមូលនិធិជនពិការ បានមកពីការឧបត្ថម្ភ និងអំណោយរបស់រាជរដ្ឋាភិបាល ស្ថាប័ន គ្រឹះស្ថានសប្បុរសជននានា គ្រប់មជ្ឈដ្ឋាន និងវិភាគទានដែលមានចែងក្នុងមាត្រា ៤០ នៃច្បាប់នេះ ។

# ជំពូកទី ១១: រដ្ឋបាលសិទ្ធិជនពិការ

**មាត្រា ៥៩.-**

រដ្ឋបាលសិទ្ធិជនពិការ ជាអង្គភាពនៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា មានភារកិច្ចជាអាទិ៍ គឺរៀបចំដាក់ឱ្យដំណើរការ សំរបសំរួល ត្រួតពិនិត្យ និងវាយតំលៃនយោបាយជាតិអំពីសិទ្ធិជនពិការ ។ នៅក្នុងវិស័យរដ្ឋបាលសាធារណៈ រដ្ឋបាលសិទ្ធិជនពិការគឺជាឧបករណ៍ដែលរៀបចំ និងអនុវត្តច្បាប់ ដើម្បីធ្វើឱ្យនយោបាយនេះទៅជាជាក់ស្តែង ។

**មាត្រា ៦០.-**

រដ្ឋបាលសិទ្ធិជនពិការ ផ្តល់ការពិគ្រោះយោបល់ដល់ជនពិការ ស្ថាប័ន គ្រឹះស្ថានសាធារណៈ ព្រមទាំងអង្គការពាក់ពន្ធ័នានា ដើម្បីលើកកំពស់កិច្ចសហការ និងកិច្ចសហប្រតិបត្តិការ សំដៅពង្រឹងប្រសិទ្ធិភាពនៃការអនុវត្តន៍ច្បាប់នេះ ។

**មាត្រា ៦១.-**

រដ្ឋបាលសិទ្ធិជនពិការផ្តល់សេវាសម្រុះសម្រួល ផ្សះផ្សា ជួយដោះស្រាយនូវវិវាទផ្សេងៗ ដែលកើតមានឡើងចំពោះជនពិការ ។

**មាត្រា ៦២.-**

រដ្ឋបាលសិទ្ធិជនពិការត្រូវមានអង្គភាពទិន្នន័យពិការភាព និងអង្គភាពអធិការកិច្ច និងសំរុះសំរួល ។

**មាត្រា ៦៣.-**

រដ្ឋបាលសិទ្ធិជនពិការ ត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវខ្លឹមសារនៃច្បាប់នេះ ព្រមទាំងច្បាប់ និង បទបញ្ញាផ្សេងៗ ទៀតដែលទាក់ទងនឹងពិការភាព ។

**មាត្រា ៦៤.-**

ការរៀបចំ និងការប្រព្រឹត្តិទៅនៃរដ្ឋបាលសិទ្ធិជនពិការ ត្រូវកំណត់ដោយប្រកាសក្រសួងសង្គមកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

## ជំពូកទី ១២: ទោសបញ្ញត្តិ

**មាត្រា ៦៥.-**

អ្នកប្រព្រឹត្តល្មើសនឹងបទបញ្ញត្តិនៃ មាត្រា ៣២ កថាខ័ណ្ឌ ៣ និង ៤ មាត្រា ៣៩ មាត្រា ៤១ មាត្រា ៤៤ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០០.០០០រៀល ដល់ ៥០០.០០០រៀល ។

**មាត្រា ៦៦.-**

អ្នកប្រព្រឹត្តល្មើស នឹងបទបញ្ញត្តិនៃមាត្រា ២២ មាត្រា ២៣ មាត្រា ៣៧ មាត្រា ៣៨ មាត្រា ៤០ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០០.០០១រៀល ដល់ ២.០០០.០០០រៀល ឬ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ថ្ងៃ ដល់ ៣ខែ ឬ ត្រូវទទួលទោសទាំងពីរ ។

**មាត្រា ៦៧.-**

កាលណាមានបទល្មើសច្រើន ហើយត្រូវតែទទួលរងដោយទោសពិន័យតាមបញ្ញត្តិនៃច្បាប់នេះ ការដាក់ពិន័យត្រូវធ្វើតាមចំនួនបទល្មើស ប៉ុន្តែមិនឱ្យលើសពី ៥ ដងនៃអត្រាអតិបរមានៃពិន័យនោះឡើយ ។

វិធាននេះត្រូវអនុវត្តជាអាទិ៍ ក្នុងករណីដែលនិយោជិតច្រើននាក់ ត្រូវគេរំលោភក្នុងលក្ខខណ្ឌផ្ទុយពីបញ្ញត្តិនៃច្បាប់នេះ ។

ក្នុងករណីពុំរាងចាល ត្រូវពិន័យតម្លើងមួយជាបី ។

**មាត្រា ៦៨.-**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០០.០០១រៀល ដល់ ២.០០០.០០០រៀល ឬ ត្រូវផ្តន្ទាទោសដាក់ ពន្ធនាគារពី៦ថ្ងៃ ដល់ ៣ខែ ឬ ត្រូវទទួលទោសទាំងពីរចំពោះជនណាដែលជំទាស់ ឬ ប៉ុនប៉ងជំទាស់នឹងការអនុវត្តន៍តាម មុខងារ ឬ ការប្រើប្រាស់អំណាច ដែលប្រគល់ឱ្យអធិការសិទ្ធិជនពិការ ។

## ជំពូកទី ១៣: អវសានបញ្ញត្តិ

**មាត្រា ៦៩.-**

បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី ...... ខែ ............. ឆ្នាំ ............
នាសម័យប្រជុំរដ្ឋសភាលើកទី ២ និតិកាលទី ....... ។
រាជធានីភ្នំពេញ,ថ្ងៃទី .... ខែ .......... ឆ្នាំ ២០០១
ប្រធានរដ្ឋសភា